# ជើងមេឃថ្មី

**និពន្ធដោយ ប៉ែន សេដ្ឋារិន**

តាមរឿងពិតរបស់នារីខ្មែរម្នាក់

# ជាបឋម

ខ្ញុំមករស់នៅស្រុកជប៉ុនក្នុងនាមជានិស្សិតដែលរដ្ឋជប៉ុនអញ្ជើញឱ្យមករៀនតាំងពីអាយុ១៨ឆ្នាំហើយត្រូវយកចំណេះវិជ្ជាដែលបានក្រេបជញ្ជក់ហើយទៅបំរើប្រជាជាតិជាកំហិត ។នៅក្នុងខួរក្បាលខ្ញុំដែលនៅទន់នៅឡើយខ្ញុំតែងតែគិតថាខ្ញុំមានកតព្វកិច្ចនឹងជួយកសាងប្រទេសកម្ពុជាដោយសុទ្ធចិត្តដើម្បីឱ្យមាតុប្រទេសបានរីកចំរើនជាអារ្យប្រទេសពិតៗ ។ប៉ុន្តែសុបិននិមិត្តរបស់ខ្ញុំបានរលត់រលាយដោយសារតែការប្រែ-ប្រួលមិនឈប់ឈរនៃស្ថានភាពនយោបាយនៅក្នុងប្រទេសកម្ពុជា ។

ខ្ញុំតែងតែរង់ចាំឱកាសដែលហុចឱ្យខ្ញុំទៅបំរើមាតុប្រទេសរបស់ខ្ញុំវិញ ទោះជាក្នុងប្រការណាមួយក៏ដោយ ។ នៅប្រទេសមួយដែលឆ្ងាយពីមាតុប្រទេសនេះ ខ្ញុំតែងតែទទួលការពឹងពាក់ឱ្យបកប្រែភាសា ពីជនជាតិខ្មែរដែលមានបញ្ហាក្នុងការរស់នៅៗប្រទេសជប៉ុនហើយដែលមិនមានលត្ថភាពអាចបង់តម្លៃបកប្រែនិងជូនកាលពីស្ថានទូតខ្មែរនៅប្រទេសជប៉ុន ហើយមានទំនុកទុកចិត្តពីអ្នកទាំងអស់ជានិច្ចជាកាល ។ ខ្ញុំបាន ជួបខ្មែរជាច្រើនហើយយើងតែងតែរាប់អានគ្នាមានទំនុកទុកចិត្តលើគ្នាទៅវិញទៅមក ដូចជាបងប្អូនគ្នា ។ ម្នាក់ៗតែងតែមកលេងនៅការិយាល័យរបស់ខ្ញុំជុំៗ។ ខ្ញុំដឹងថានៅ ពេលដែលយើងនៅឆ្ងាយពីមាតុប្រទេស យើងមានការត្រម៉ង់ត្រមោចទាំងចិត្តទាំងកាយ ហើយយើងត្រូវការជួបជុំបំភ្លេចទុក្ខ ឬក៏ចង់ដឹងនូវសភាពពិតនៃសង្គមដែលយើងរស់នៅពីព្រោះយើងមានការបារម្ភចំពោះច្បាប់ទំលាប់នៃប្រទេសគេដែលខុសពីយើង ។ខ្ញុំតែងតែ និយាយពន្យល់ហើយដោះស្រាយជាមួយគ្នា នូវបញ្ហា

ដែលមិនសូវជាមានទំនាក់ទំនងនឹងបញ្ហារដ្ឋាបាលប៉ុន្មាន ។ ដោយខ្ញុំមិនដែលបាន ស្គាល់ជំនាន់ពល់ពតជួនកាលបងប្អូនយើងលើកយករឿងកំសត់ដែលគេម្នាក់ៗបានជួប ប្រទះនៅជំនាន់ពល់ពតហើយសរសើរខ្ញុំដែលមិនបានស្គាល់អាពតដូចគេ ។ ខ្ញុំតែងតែកត់ត្រាទុកនូវរឿងរ៉ាវ ផ្សេងៗទុកទាំងអស់ ។

រឿងដែលមនុស្សយើងជួបប្រទះទោះជាមានករណីយ៍ដូចគ្នាក៏ដោយក៏មានពេល ខ្លះមានកំហុសគ្នាដោយកន្លែងខ្លះហើយជួនកាលយើងអាចដោះស្រាយបានដោយសារ តែការខិតខំការព្យាយាម ។

ក៏ប៉ុន្តែនៅពេលដែលខ្ញុំស្តាប់រឿងដែលអារីយ៉ាឡារ៉ាត់រៀបរាប់ប្រាប់ ខ្ញុំមិនអាច ទប់ចិត្តមិនឱ្យរញ្ជួយបានឡើយ ។ វាសនារបស់នាង ហាក់ដូចជាត្រូវកំណត់ ដោយយើងម្នាក់ៗដែលនាងមកពិគ្រោះ ។ ទោះបីនាងខិតខំប្រឹងប្រែងយ៉ាងណាក្តី បើយើងមិនរវីរវល់នឹងនាង ជីវិតនាងនឹងត្រូវក្រឡះពីសទៅខ្មៅបាន ។ ខ្ញុំសំរេចចិត្តសរសេររឿងនាងទុកជាកំណត់ហេតុមួយដែលជាផលវិបាកនៃមនោគម វិជ្ជានិងសង្គ្រាម ។

យើងបានស្គាល់គ្នាដោយសារស្ថានទូតខ្មែរតូក្យូដែលទូរស័ព្ទមកពឹងពាក់ឱ្យ ខ្ញុំជួយធ្វើសម្ភាស ជាមួយនឹងនាងដើម្បីឱ្យដឹងថាតើនាងពិតជាជនជាតិខ្មែរមែនឬមិនមែន ។ ស្ថានទូតខ្មែរក៏បានឱ្យបុគ្គលិកពីរបីនាក់សម្ភាសជាមួយនាងស្រេចបាច់ហើយដែរ តែគេត្រូវ ការការបញ្ជាក់ពី អ្នកមានបទពិសោធន៍និងអ្នកចេះដឹងខាងសង្គមវិជ្ជាផងក៏មិនដឹងទើប បាន ជាគេឱ្យលេខទូរស័ព្ទនាងមកខ្ញុំ ។ដោយខ្ញុំចេះភាសាថៃបន្តិចបន្តួចខ្ញុំបាននិយាយសាកសួរអារី

យ៉ាឡា៉ាត់ឱ្យរៀបរាប់ពីជីវប្រវត្តិរបស់នាង ។អារីយ៉ាបាន និយាយប្រាប់ខ្ញុំជាភាសាថៃហើយជួនកាលនឹកឃើញភាសាខ្មែរមួយម៉ាត់ៗហើយបានអនុញ្ញាតឱ្យខ្ញុំសរសេរជាសៀវភៅ ដើម្បីឱ្យ គេឯងបានដឹងពីរឿងរបស់នាងក្រែងអាចជាគំនិតមួយ ។

អ្នកនិពន្ធ

# ជំពូកទី១

សង្គ្រាម

ខ្ញុំឈ្មោះឈួន អារីយ៉ាឡាត់ ឪពុកឈ្មោះឈួន សុផល ម្តាយឈ្មោះឡាយហៀង ។ ខ្ញុំកើតនៅខេត្តកំពង់ចាម ។ ឪពុកខ្ញុំធ្វើពេទ្យមានផ្ទះពេទ្យមួយនៅកំពង់ចាម ។ ខ្ញុំនឹងនិយាយពីអ្វីដែលខ្ញុំចាំប្រាប់បង ។

នៅពេលដែលលោកលន់នល់ឡើងធ្វើប្រធានាធិបតេយ្យសាធារណរដ្ឋខ្មែរនៅឆ្នាំ ១៩៧០ ប្រទេសខ្មែរក៏កើតសង្គ្រាមហើយផ្ទះពេទ្យរបស់យើងមួយថ្ងៃៗ ពោរពេញទៅដោយទាហានដែលមានរបួសដាបដោយឈាមគួរឱ្យរន្ធត់ ។នៅពេលនោះខ្ញុំមានអាយុ៨ឆ្នាំ ។សង្គ្រាមបានរាលធំឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ។ឪពុកខ្ញុំបានត្រូវរដ្ឋាភិបាលហៅឱ្យទៅព្យាបាលទាហានរបួសនៅសមរភូមិ ។គេបានបំពាក់សក្តិជាឧត្តមសេនីយ៍ឯកដល់គាត់ ។

គ្រាប់ផ្លោងធ្លាក់ប្រសាចជារៀងរាល់ថ្ងៃហើយមនុស្សជាច្រើនស្លាប់យ៉ាងអាណោចអាធមិ ។ គ្រាប់ផ្លោងទាំងនេះធ្លាក់មិនឈប់ជួនកាលនៅចំពីមុខផ្ទះយើងតែម្តងក៏មានដែរ ។ ខ្ញុំខ្លាចញ័រញាក់ដូចគេបញ្ឆាន់មេមត់ស្រែកយំព្រោះសម្លេងនោះឮសូរគ្រាំងខ្លាំងពេកស្ទើរតែបែកក្រដាសត្រចៀក ។

ដោយអាណិតខ្ញុំផងនិងដោយបារម្ភពីអាយុជីវិតរបស់គ្រួសារផងឪពុកខ្ញុំបានទិញផ្ទះមួយនៅ ម៉ុផ្ទះ១០០ខ្នងដែលនៅជាយទីក្រុងភ្នំពេញឱ្យខ្ញុំនិងម្តាយខ្ញុំរស់នៅ ។ ជីវភាពនៅភ្នំពេញមិនជាសប្បាយប៉ុន្មានទេព្រោះយូរៗទើបខ្ញុំអាចជួបឪពុកខ្ញុំម្តង ។ នៅពេលដែលឪពុកខ្ញុំមកពីសមរភូមិម្តងៗកូនទាហានទាំងឡាយដែលមកតាមគាត់ក៏មកនៅគេងផ្ទះយើង ហើយ ផ្ទះ

យើងកឡើងអ៊ូរអរដូចជាផ្សាររាត្រី ។ ពេលមកផ្ទះម្តងៗឪពុកខ្ញុំចូលចិត្តឱបត្រកងខ្ញុំ ហើយសួរដដែលៗថា "អារីយ៉ាធំឡើងចង់ធ្វើអ្វី? ចង់ធ្វើពេទ្យឬ? ឪពុកខ្ញុំសួរ ហើយឆ្លើយខ្លួនឯងជារឿយៗបែបនេះ ។

ខ្ញុំដឹងថាឪពុកខ្ញុំច្បាស់ជាចង់ឱ្យខ្ញុំធ្វើពេទ្យប៉ុន្តែដោយសារតែឪពុកខ្ញុំឆ្លើយជំនួសខ្ញុំគ្រប់យ៉ា-ងបែបនេះ ខ្ញុំក៏គ្មានឱកាសនឹងឆ្លើយហើយក៏មិនដែលមានឱកាសនឹងគិតដែរ។ ខ្ញុំរៀននៅសាលាបឋមសិក្សាថ្នាក់ទី១០( សព្វថ្ងៃគេហៅថាថ្នាក់ទី៣) ដែលនៅមិនឆ្ងាយពីផ្ទះ១០០ ខ្នងនោះប៉ុន្មានទេ ។កូនទាហានតែងតែបើកឡានជូនខ្ញុំទៅដាក់សាលាហើយមកចាំយកខ្ញុំនៅពេលដែលខ្ញុំចេញពីសាលា។ ខ្ញុំស្គាល់តែជីវភាពបែបនេះហើយមិនដែលធ្វើការដាំដុះឬក៏ ដើរទៅទីកន្លែងឆ្ងាយៗតែឯងឡើយ។

នៅខែមេសាឆ្នាំ១៩៧៥នៅពេលជិតចូលឆ្នាំខ្មែរម្តាយខ្ញុំប្រាប់ខ្ញុំថាឪពុកខ្ញុំជិតមកផ្ទះហើយ ហើយគាត់បានឱ្យកូនគូលីទាំងឡាយ បោស សំអាតផ្ទះជូតទ្វាជូតបង្អួចប្តូរវាំងននឡើងស្អាត ។ កូនគូលីដែលធ្វើសួនកាត់តំរឹមដើមឈើឱ្យឡើងកន្ទុលៗ ធ្វើជារាងសត្វឈ្លូសឬជារាងសត្វផ្សេងៗហើយបំពាក់ខ្សែភ្លើងដែលមានកូនអំពូលតូចៗឱ្យភ្លឺភ្លឹបភ្លែតៗ ។ សត្វដែលធ្វើពីដើមឈើហើយភ្លឺភ្លឹបភ្លែតៗនេះធ្វើឱ្យខ្ញុំសប្បាយចិត្តជាងអ្វីទាំងអស់។
ខ្ញុំដឹងថាមនុស្សដែលនៅជុំវិញខ្ញុំតែងតែ សប្បាយចិត្តនៅពេលដែលខ្ញុំសប្បាយ។

ខ្ញុំទន្ទឹងមើលផ្លូវឪពុកខ្ញុំមួយថ្ងៃជាមួយថ្ងៃ រហូតដល់ថ្ងៃមុនចូលឆ្នាំពីរអាទិត្យ។ ទោះបីជាស្រុកមានសង្គ្រាមគ្រាប់បែកផ្លោងចូលមកមួយថ្ងៃ៣-៤ដងក្តីក៏អ្នកភ្នំពេញហាក់ដូចជាលែងភ្ញាក់ផ្អើលលែងញញើតនឹងការស្លាប់ ការវិនាស ហើយប្រពៃណីដែលតែងតែប្រព្រឹត្ត

ទៅដូចជាការរាំកំសាន្តក្តី ល្បែងស៊ីសងនៅលើផ្លូវថ្នល់ក្តីនៅតែប្រព្រឹត្តដូចធម្មតាមានមនុស្ស អ៊ូរអ៊ូរស្រែកហ៊ោរ កញ្ជ្រៀវសប្បាយជាធម្មតា ។

មុនចូលឆ្នាំពីរអាទិត្យមានឡានទាហានមួយបរមកឈប់នៅមុខផ្ទះយើង ។ខ្ញុំអររខិបរខុប រត់ត្រេសំដៅទៅរបងគិតថាច្បាស់ជាឳពុកខ្ញុំត្រឡប់មកវិញហើយ ។

ប៉ុន្តែអ្នកដែលចុះពីលើឡានមកមិនមែនជាឳពុកខ្ញុំទេគឺជាទាហានមាឌធំម្នាក់ដែលខ្ញុំមិនដែល ឃើញ ។ គាត់លើកដៃគំនាប់ ហើយដើរចូលមកក្នុងផ្ទះ យើង ។

គាត់និយាយខ្សឹប១ជាមួយម្តាយខ្ញុំ ។ខ្ញុំឃើញម្តាយខ្ញុំទំលាក់ខ្លួនទៅលើកៅអីវែង ហើយ យំខ្សឹកខ្សួល ។ខ្ញុំអាចស្មានបានពីអ្វីដែលកើតឡើង ។ទាហានដែលមានមាឌធំក្រោយពីបាន និយាយជាមួយម្តាយខ្ញុំហើយក៏លើកដៃគំនាប់គោរពលាម្តាយខ្ញុំ ត្រឡប់ក្រោយបែរ ហើយឡើងឡានចេញទៅវិញបាត់ទៅ ។ខ្ញុំដើរទៅជិតម្តាយខ្ញុំឱនមើលគាត់ ។ខ្ញុំបារម្ភខ្លាំង ណាស់ ។ ម្តាយខ្ញុំលែងរវីរវល់នឹងអ្វីហើយ ។ មើលទៅគាត់ហាក់ដូចជាគល់ឈើឬក៏ជារុក្ខជាតិ ដែលគេកាប់រំលើងទុកចោលក្រោមពន្លឺថ្ងៃឡើងស្វិតទ្រោម ។ ខ្ញុំយកដៃអង្អែលមុខគាត់ ថ្នម១ ។ ខ្ញុំអាណិតម្តាយខ្ញុំជាខ្លាំង ។ ម្តាយខ្ញុំនិយាយតិច១ថា " ប៉ាកូនឯងស្លាប់ហើយ " ។ ឳពុកខ្ញុំបានទទួលមរណភាព ដោយសារតែត្រូវគ្រាប់ដែលបំបែ្លងពីណាពីណើមក ។ខ្ញុំមើល មុខម្តាយខ្ញុំហើយខ្ញុំភ័យខ្លាចតែម្តាយខ្ញុំស្លាប់ដែរ ។ ខ្ញុំដឹងថាមនុស្សតែស្លាប់ហើយ មិន អាចវិលត្រឡប់មកវិញបានទេប៉ុន្តែខ្ញុំមិនដែលគិតថាជីវិតមួយអាចកែប្រែក្រឡាប់ផ្កាប់ផ្ងារ ពីខ្ពស់ទៅទាបពីល្អទៅអាក្រក់ពីធំទៅតូចយ៉ាងឆាប់រហ័សដោយសារតែមរណៈភាពរបស់ បុគ្គលម្នាក់ឬក៏ដោយសារតែរបបនយោបាយមួយឡើយ ។ ឆាកជីវិតដែលខ្ញុំបានជួប

ផ្ទាល់ខ្លួនខ្ញុំនេះជាសាក្សីប្រត្យ័ក្សដើម្បីឱ្យមនុស្សម្នាក់ៗគិត ។ ពេលនោះ ខ្ញុំនៅតូចហើយខ្ញុំមិនដែល សើចចំអកឱ្យនរណាម្នាក់ដែលស្ថិតនៅក្នុងសភាពលំបាកឬក៏សំឡាប់សត្វអ្វី មួយឡើយប៉ុន្តែ តើហេតុអ្វីបានជាខ្ញុំត្រូវតែទទួលពៀរដ៏ក្រាស់ឃ្មឹករកតែងើបមុខមិនរួចបែបនេះ។ ឬមួយខ្ញុំប្រព្រឹត្តអំពើបាបកាលពីជាតិមុនឬយ៉ាងណាបានជានៅជាតិនេះជីវិតខ្ញុំពោរពេញទៅដោយទុក្ខសោកមិនចេះចប់បែបនេះ ។ បើដូច្នេះមែនគឺជាប្រស្នាមួយដែលយើងគ្រប់រូបគួរតែគិត។ ខ្ញុំមិនអាច សរសេរបានទេ ពីព្រោះខ្ញុំភ្លេចភាសាខ្មែរ ខ្ញុំភ្លេចអក្សរខ្មែរអស់ហើយ។ រហូតមកដល់ពេល នេះខ្ញុំមិនដែលបានទទួលឱកាសសិក្សាទេព្រោះខ្ញុំជាមនុស្សគ្មានបញ្ជីជាតិគ្មានសញ្ជាតិ ជាមនុស្សក្បាលមួយដែលដើរតគ្រាក់គ្មានទិសដៅហើយត្រូវគេមើលងាយដូចឆ្កែ ដំបៅក្បាល ។

នៅពេលដែលឪពុកខ្ញុំស្លាប់ចោលយើងទាំងពីរទៅជីវិតយើងសែនតែលតោលដូចចកដែលរសាត់តាមខ្សែទឹកក្នុងមហាសាគរ។ ខ្ញុំបានដឹងថាអ្វីៗទាំងអស់ដែលខ្ញុំបានទទួលដូចជាជីវ-ភាពដ៏ស្រណុកសុខសាន្តជាអិទ្ធិពលរបស់ឪពុកខ្ញុំហើយវាបានបាត់បង់ទៅព្រមគ្នានឹងពេលដែលឪពុកខ្ញុំស្លាប់។ ជីវិតយើងឡើងល្ហល្ហេវដូចមហាសមុទ្រដែលមើលត្រើយមិនឃើញ។ ការបាត់បង់សម្បត្តិទ្រព្យបុណ្យសក្តិក៏នាំឱ្យយើងល្ហល្ហេវតែលតោលដែរ ប៉ុន្តែ ការបាត់បង់បង្អែក និងចន្ទល់នៃដួងចិត្តធ្វើឱ្យយើងវិនាសពិតប្រាកដតែម្តង ។ ប៉ុន្តែពេលនោះខ្ញុំ នៅតូចណាស់ ខ្ញុំគ្មានប្រាជ្ញាឬក៏កំឡាំងសំរាប់លួងលោមម្តាយខ្ញុំឱ្យគាត់ហ្នឹងហ្មចិត្តបានទេ។

# ជំពូកទី២

## ខ្លួងដាច់ខ្សែ

នៅពេលដែលយើងធ្វើបុណ្យសពឪពុកខ្ញុំបានមិនទាន់បីថ្ងៃផងថ្ងៃទី១៧ខែមេសាបានចូលមកហើយកងទ័ពរបស់អាពតបានចូលមកក្នុងទីក្រុងភ្នំពេញ។ គេបានជន្លៀសយើងទាំងពីរនាក់ម្ដាយកូនឱ្យទៅនៅខេត្តពោធិសាត់ ។ នៅទីនោះគេឱ្យខ្ញុំធ្វើការងារស្រែ ចំការនៅកងកុមារឆ្ងាយពីម្ដាយខ្ញុំ។ គេឱ្យខ្ញុំឃ្វៀលគោផង ស្ទូងផង។ ខ្ញុំខ្លាចឈ្លើងណាស់ដូច្នេះខ្ញុំតែងតែគេចមិនចូលទៅស្ទូងទេ ។ខ្ញុំទៅជិតគោ ដេកក្បែរជើងគោ ។ខ្ញុំភ័យខ្លាចតែគោជាន់ខ្ញុំប៉ុន្តែសំណាងល្អវាមិនដែលជាន់ខ្ញុំទេ។

ដល់ពេលបាយខ្ញុំដឹកគោទៅរោងបាយខ្ញុំហេវឃ្លានបាយខ្លាំងណាស់ ។ប៉ុន្តែមេកងនិយាយថា "ហងឯងអត់ធ្វើការគ្មានរបបស៊ីទេ។ ខ្ញុំព្រួតែប៉ុណ្ណេះអួលដើមក។ ទឹកភ្នែកខ្ញុំហូរមកច្រោក១ ។ខ្ញុំមិនដែលមាននរណាហៅមឹងហងដាច់សាច់បែបនេះទេម្យ៉ាងទៀតពោះខ្ញុំកូរគ្រូក១ ។ខ្ញុំឃ្លានខ្លាំងណាស់។ មេកងដូចជាអាណិតខ្ញុំហុចបាយឱ្យខ្ញុំមួយស្លាបព្រា។ ខ្ញុំឃ្លានពេកខ្ញុំទទួលបាយមួយស្លាបព្រានោះមកពម។ ប៉ុន្តែពោះខ្ញុំនៅតែកូរខ្ញុំនៅតែឃ្លាន ។ខ្ញុំដើរលប១ចេញពីរោងបាយទៅឃើញដំឡូងមួយកំណាត់ដែលគេធ្វើធ្លាក់ ។ខ្ញុំរើសដាក់ថ្ពក់ខោចិនខ្ញុំ។ ពេលយប់នោះខ្ញុំលួចរត់ពីកន្លែងកងកុមារដើរកាត់អន្ធការទៅ រកម្ដាយខ្ញុំ ។រាល់ដងខ្ញុំតែងតែខ្លាចសូម្បីតែសំឡេង តុកកែយំក៏ខ្ញុំខ្លាចដែរកុំថាឡើយឱ្យដល់ទៅដើរកាត់ព្រៃក្លុងងងឹតស្លុបព្ទសូរតែទីទុយនិងក្លែងស្រោកយំ។ ប៉ុន្តែខ្ញុំនឹកម្ដាយខ្ញុំណាស់ ខ្ញុំចង់យំតំអូញរៀបរាប់ពីទុក្ខខ្ញុំឱ្យម្ដាយខ្ញុំដឹង ឱ្យម្ដាយខ្ញុំជួយអាណិតខ្ញុំ

ហើយម្យ៉ាងទៀតខ្ញុំមានដំឡូងសំរាប់យកទៅផ្ញើរគាត់ផង។ ខ្ញុំបានឃើញថាតាំងពីធ្វើបុណ្យសពឪពុកខ្ញុំរួចហើយមកម្តាយខ្ញុំមានទុក្ខសោករហូត។ នៅពេល ដែលគេជន្លៀសឱ្យដើរតាមផ្លូវម្តាយខ្ញុំគ្មានកម្លាំងដើរ ដើរដួល។ ។នៅពេលនោះខ្ញុំដាក់គូថអង្គុយក្បែរគាត់មើលមុខគាត់ភ្លឹះ។ ។ម្តាយខ្ញុំគិតតែពីឱបក្រសោបខ្ញុំយំខ្សឹកខ្សួលគ្មាននិយាយអ្វីទាំងអស់។

នៅពេលទៅនៅការដ្ឋាន គាត់មិនអាចធ្វើការបានហើយមិនអាចទទួលរបបគ្រប់គ្រាន់ឡើយ ។គាត់តែងតែរង់ចាំបញ្ញើបន្តិចបន្តួចពីខ្ញុំដូចជាដំឡូងជាដើមដែលខ្ញុំលួចលាក់ទុក។ យប់នោះនៅពេលដែលឃើញខ្ញុំ ម្តាយខ្ញុំស្ទុះមកឱបខ្ញុំ ហើយប្រវេប្រវាស្រាយថ្នក់ក្រមាខ្ញុំក្តាប់ដំឡូងមួយកំណាត់នោះខាំលេបទាំងសំបកព្រោះគាត់អត់ឃ្លានខ្លាំងណាស់។ គាត់ ទំពារដំឡូងទាំងឆៅគ្រឹត។មើលទៅឃើញគួរឱ្យអនិច្ចាណាស់។ នៅពេលដែលគាត់ពិសាររួចហើយគាត់ក៏ឱបពោះថ្ងូររួចហើយទំរេតទៅលើកន្ទេលកញ្ចាស់ដែលក្រាលលើរនាបពុក។ ខ្ញុំលូនទៅគេងត្រៀវនក្បែរគាត់រហូតដល់ភ្លឺស្រាង។ម្តាយខ្ញុំក៏ដាស់ខ្ញុំឱ្យខ្ញុំរូតរាន់ទៅកន្លែងកុមារវិញ។ នៅលើកបន្ទាប់នៅពេលដែលគេអនុញ្ញាតឱ្យទៅលេងភូមិអ្នកភូមិគេ បានប្រាប់ខ្ញុំថាម្តាយខ្ញុំស្លាប់បាត់ ហើយ។ ម្តាយខ្ញុំមិនដឹងជាស្លាប់ដោយជម្ងឺឬដោយសារអ្វីទេ។ ម្នាក់។និយាយរឿងដូចជាវាំហឺ ហាក់ដូចជាមរណភាពរបស់មនុស្សម្នាក់។ជាការ ស្លាប់របស់សត្វធាតុ ហើយគេគ្មានទាំងអនិច្ចាពីចិត្តសោកសង្រេងរបស់ខ្ញុំជាកុមារម្នាក់ ដែលក្លាយទៅជាខ្ទួងដាច់ខ្សែរស់តែឯង អណ្តែតដូចចកតែលតោលឡើយ។

ក្រោយពេលដែលម្តាយខ្ញុំស្លាប់ទៅខ្ញុំហាក់ដូចជាមិនមានអារម្មណ៍នឹងហ្មទេ ខ្ញុំហាក់ដូចជាលែងចង់រស់នៅ ហើយគិតថាខ្ញុំចង់ស្លាប់។ ខ្ញុំចង់ទៅនៅជាមួយនឹងម្តាយរបស់ខ្ញុំ ទោះជានៅ

ស្ថានណាក្តី ។ នៅពេលស្ទូងដោយខ្ញុំខ្លាចឈ្លើងខ្លាចដង្កូវខ្ញុំមិនហ៊ានចុះទៅក្នុងស្រែទេ ខ្ញុំគិតថាលើកនេះបើគេយកខ្ញុំទៅសំឡាប់ក៏យកទៅចុះឱ្យខ្ញុំបានទៅជួបម្តាយខ្ញុំនៅស្ថានដែលម្តាយខ្ញុំទៅនៅ ។នៅពេលដែលអ្នកទាំងឡាយហូបបាយ ខ្ញុំហេវបាយណាស់តែខ្ញុំដឹងថាថ្ងៃនេះក៏ខ្ញុំគ្មានរបបដែរ ព្រោះមេកងខ្ញុំដឹងច្បាស់ថាខ្ញុំមិនបានចូលទៅក្នុងស្រែស្ទូង នឹងគេនឹង ឯងទេ ។ខ្ញុំឡើងធេងធោង ។បើខ្ញុំមិនទទួលទានអ្វីទេខ្ញុំច្បាស់ ជានឹងដួលស្រូសហើយ ។ ខ្ញុំនឹកឃើញចំការសណ្តែក ។ខ្ញុំដើរលបៗទៅចំការសណ្តែក ។ងាកមើលឆ្វេងស្តាំឃើញថាគ្មានមនុស្សទេខ្ញុំក៏លោទៅបូតសណ្តែកបានមួយក្តាប់យកមកប្រឡេះអក ។ នៅពេលដែលខ្ញុំកំពុងតែអកសណ្តែកស្រាប់តែមានពូម្នាក់ស្ទុះចេញមិនដឹងជាពីទីណាមកទេ ។ គាត់យករំពាត់វាត់វៃខ្ញុំដាច់សាច់មានឈាមចេញមករហាច ។ខ្ញុំយកដៃខ្ញុំរាំងខ្លួនប្រាណខ្ញុំដែលត្រូវគេវាត់វាយឡើងសុះសព្វសាច់ ។ស្នូររំពាត់ធ្លាក់ព្វតែខ្ទាប់ៗលើដៃដ៏តូចៗរបស់ខ្ញុំ ។ដៃខ្ញុំឡើងស្រពន់ឈឺចុកចាប់ផ្សារពើត ។ ខ្ញុំដួលស្រូសតែខ្ញុំខំ ខាំមាត់អត់ទ្រាំមិនយំឱ្យចេញសម្លេងទេ ។ពូនោះបានចាប់ក្របួចកអាវខ្ញុំលើក ខ្ញុំអង្រួនហើយបោកខ្ញុំទៅលើដីហើយថានឹងឱ្យគេយកខ្ញុំទៅដាក់គុកលេខ៨២( នៅពោធិសាត់) រួចហើយនឹងឱ្យគេសំឡាប់ខ្ញុំ ។ ខ្ញុំលែងខ្លាចស្លាប់ហើយព្រោះខ្ញុំព្វពាក្យនេះសឹងតែរាល់ថ្ងៃ ខ្ញុំស៊ាំហើយៗណាមួយខ្ញុំគ្មានចិត្តចង់រស់សូម្បីតែបន្តិចក៏គ្មានដែរ ។ពេលនោះគេបាន យកខ្ញុំទៅឱ្យយោធា ។ពូយោធានោះមិនយកខ្ញុំទៅដាក់គុកទេគាត់យកខ្ញុំទៅផ្ញើនឹងប្រពន្ធគាត់ ។គាត់ឱ្យបាយខ្ញុំហូប ខ្ញុំបានឆ្អែតបានធូរចិត្ត បានសប្បាយចិត្ត ។ ខ្ញុំនៅទីនោះបានមួយស្របក់កងទ័ពយួនក៏ចូលមក ។ យោធាប្តីប្រពន្ធដែលបានថែ

វក្សាខ្ញុំមិនដឹងជាទៅណាបាត់ ។ដោយខ្ញុំគ្មានអ្នកអាណាព្យាបាលគេក៏បានយកខ្ញុំទៅដាក់នៅកុមារកំព្រា ។ នៅទីនោះមានក្មេងច្រើនណាស់ ។ ក្មេងតូចក៏មាន ក្មេងធំ ក៏មាន ។ ក្មេងទាំងឡាយតែងតែរង់ចាំម្ដាយឪពុកមករក ។ដោយខ្ញុំគ្មានឪពុកម្ដាយខ្ញុំត្រូវរង់ចាំអ្នកអត់កូនឯណាដែលចង់បានកូនមកទទួលយកទៅធ្វើជាកូន ចិញ្ចឹមរបស់គេ ។ មានប្ដីប្រពន្ធពីរនាក់បានមកសុំខ្ញុំយកឱ្យទៅនៅជាមួយគេ ។ ប្រធានមន្ទីបានឱ្យខ្ញុំទៅនៅជាមួយនឹងគេ ។ អ្នកទាំងពីរមកសុំខ្ញុំដើម្បីឱ្យជួយជំនួសដៃជើងគេ មិនមែនយកខ្ញុំទៅថ្នាក់ថ្នមដូចម្ដាយឪពុករបស់ខ្ញុំទេ ។ ខ្ញុំធ្វើការបំរើឪពុកម្ដាយថ្មីរបស់ខ្ញុំ ជួយរែកទឹកដាំបាយបោកគក់ខោអាវ ។មានថ្ងៃមួយ ខ្ញុំឮម្ដាយឪពុកចិញ្ចឹមខ្ញុំនិយាយខ្សឹបខ្សៀវគ្នាថានឹងនាំគ្នារត់ទៅលិច ។ យើងបានដើរពីពោធិសាត់កាត់ព្រៃ ទាំងខ្សែៗដូចគេហែរកចិន ។ ខ្ញុំហត់ហេវខ្លាំងណាស់ប៉ុន្តែខ្ញុំមិនហ៊ានត្អូញត្អែរទេព្រោះខ្លាចចិត្តឪពុកម្ដាយចិញ្ចឹមខ្ញុំ ។ ឪពុកម្ដាយចិញ្ចឹមខ្ញុំស្ពាយផងរែកផងពុនផង ។ខ្ញុំទូលរបស់របរដែលឪពុកម្ដាយចិញ្ចឹម ខ្ញុំកាន់មិនអស់ ។នៅតាមផ្លូវយើងត្រូវដាំបាយហូប ។ ប៉ុន្តែគ្មានទឹកស្អាតទេ ។ ឪពុកម្ដាយខ្ញុំប្រើខ្ញុំឱ្យទៅរកទឹក ។ ជួនកាលខ្ញុំប្រទះឃើញខ្មោចដែលហើម ស្ពឹងៗស្លាប់ ដោយចោរប្លន់ ឬដោយជម្ងឺ ។ ខ្ញុំខ្លាចសឹងតែបះសក់ ។

អ្វីៗដែលយើងឆ្លងកាត់ប្រៀបបាននឹងរឿងភាពយន្ត ហើយយើងគឺជាអ្នកដើរតួក្នុងភាពយន្តនោះតែម្ដង ។

ការដើរមិនឈប់ឈរនេះនាំឱ្យខ្ញុំមានការហត់ហេវណាស់ ។ ទោះជាយប់ឬថ្ងៃខ្ញុំតែងតែងងុយ ហើយទទួលទានដំណេកនៅលើដី ។ មានពេលមួយ នៅពេលដែលខ្ញុំ

ភ្ញាក់ឡើង ស្រាប់តែបាត់ឪពុកម្តាយចិញ្ចឹមរបស់ខ្ញុំ ។ ខ្ញុំចាប់ផ្តើមហេលហាលជាថ្មីទៀតហើយ។ ខ្ញុំមិនដឹងជាត្រូវរំពឹងទៅលើអ្នកណាទេ ។ ខ្ញុំឃើញមនុស្សធំៗទាំងឡាយអង្គុយដំកង់ទទួលទានបាយជាមួយគ្រួសារគេ ។ ខ្ញុំលេបទឹកមាត់ក្លើកៗ។ ខ្ញុំអង្គុយច្រហោងមើលមាត់គេទាំងឡាយដែលទទួលទានអាហារ ។ អ៊ុំស្រីម្នាក់និយាយថា" កូនអ្នកណាគេវ៉ិ ?មើលបោះឱ្យវាស៊ីបន្តិចទៅកុំឱ្យវាមើលៗតែដឹងចក់"។

ខ្ញុំមិនមែនជាសត្វទេ ពាក្យដែលគេនិយាយដូចជានិយាយចំពោះសត្វ ។ប៉ុន្តែខ្ញុំឃ្លានណាស់ខ្ញុំគ្មានពេលវេលានឹងឈឺចិត្តឆ្អិតទ្រូងនឹងពាក្យសម្តីមនុស្សទេទោះជាគេចាត់ទុកខ្ញុំថាជាសត្វឬជាស្អីក៏ដោយក៏ខ្ញុំលែងមានការខ្មាស់អៀនទៀតហើយ។ អ្វីដែលខ្ញុំត្រូវការគឺម្ហូបអាហារដើម្បីចំអែតក្រពះរបស់ខ្ញុំ។ ខ្ញុំបានចាប់អារម្មណ៍ថាសេចក្តីខ្មាស់អៀនលែងមានចំពោះមនុស្សដែលអត់ឃ្លានហើយ ។កូនស្រីរបស់គេបានហុចបាយនិងកូនត្រីមួយមកឱ្យខ្ញុំ ។ខ្ញុំសំពះអរគុណគេ ហើយទទួលយកបាយមកទទួលទាន។

ខ្ញុំរស់បែបនេះមិនដឹងជាប៉ុន្មានថ្ងៃទេ ។ មនុស្សទាំងឡាយមានមេត្តាចំពោះកុមារដែលវង្វេងឪពុកម្តាយហើយដាក់បាយឱ្យហូបតាមដែលគេមាន ។ប៉ុន្តែគេក៏មិនមែនគិតថាយើងជាកូនគេឬក៏ជាសាច់ញាតិគេដែរ ។យើងគឺយើងក្មេងកំព្រាដែលគេប្រោសប្រណីម្តងម្កាលតែប៉ុណ្ណោះ។ ខ្ញុំហត់ហេវណាស់នៅពេលដែលខ្ញុំដើរយូរឆ្ងាយបែបនេះ ។ ខ្ញុំតែងតែគេងលង់លក់ជារឿយៗ។ នៅពេលមួយ ខ្ញុំទទួលទានដំណេកលក់មិនដឹងខ្លួនស្រាប់តែមានទាហានម្នាក់មកដាស់ខ្ញុំ ។ ទាហាននោះសួរខ្ញុំថាទៅណា? ឯណាម្តាយឪពុក?ប៉ុន្តែភាសាខ្មែររបស់គាត់មិនមែនភាសាខ្មែរដែលខ្ញុំតែងតែឮគេនិយាយទេ។

ខ្ញុំឆ្លើយថា ខ្ញុំមិនដឹងទេ ខ្ញុំគ្មានម្តាយឪពុកទេ ។

ទាហានបានយកខ្ញុំទៅផ្ញើរនឹងម្តាយរបស់គាត់ ។ ម្តាយរបស់គាត់ក្រ គ្មានត្រីគ្មានសាច់ហូបទេ គាត់ហូបបាយជាមួយនឹងអំបិលម្ទេស ហឹរណាស់ ។ ខ្ញុំសឹងតែយំនៅពេលបាយម្តងៗ ។ ខ្ញុំប្រាប់គាត់ថាខ្ញុំមិនចេះហូបហឹរទេ ។ គាត់ខឹងខ្ញុំហើយថាបើមិនចេះស៊ីទេ ទៅស៊ីឈ្នួលគេយកបាយស៊ីទៅ ។

ខ្ញុំបានទៅធ្វើការស៊ីឈ្នួលដាំអំពៅឱ្យគេជាមួយនឹងមនុស្សធំជិតទង់ ក្រមុំកម្លោះ៤-១០នាក់ ។ នៅពេលនោះខ្ញុំបានយកត្រកូលរបស់ម្តាយទាហាន ហើយខ្ញុំមានឈ្មោះថា ឆរី ម៉ានីវ៉ាន់ ។នៅពេលដែលខ្ញុំ ធ្វើការបានពីរបីខែ ខ្ញុំបានស្គាល់ជិតស្និទ្ធជាមួយនឹងបងស្រីម្នាក់ឈ្មោះសុនសន្តាន ។នៅពេលសំរាកហូបបាយបងសុនសន្តានតែងតែនិ-យាយពីស្រុកកំណើតរបស់គាត់ឱ្យខ្ញុំស្តាប់រហូតដល់ខ្ញុំយល់សប្តិឃើញស្រុកកំណើតរបស់គាត់ហើយខ្ញុំតែងតែគិតថា នៅពេលដែលគាត់ត្រឡប់ទៅស្រុកកំណើតគាត់ខ្ញុំនឹងសុំគាត់ទៅជាមួយដែរហើយ ។នៅរដូវស្ទូងកម្មករទាំងឡាយនាំគ្នាត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ ។ខ្ញុំមិនទៅផ្ទះរបស់ម្តាយទាហានវិញទេខ្ញុំ បានសុំបងសុនសន្តានទៅនៅជាមួយ ។គាត់បានអនុញ្ញាតឱ្យខ្ញុំទៅ ។ប៉ុន្តែខ្ញុំពុំមានសេចក្តីសុខសប្បាយដូចបានឮបងសុនសន្តាននិយាយប្រាប់ទេ ។ ភូមិដែលបងសុនសន្តាននៅក្រីក្រ គ្មានអាហារគ្មានអង្ករគ្រប់គ្រាន់ហើយបងសុនសន្តានក៏មិនស្រឡាញ់ខ្ញុំដូចពីកាលដែលគាត់នៅធ្វើការដាំអំពៅជាមួយខ្ញុំឯស៊ីរិនដែរ ។ គាត់តែងតែប្រើពាក្យអសុរសមកលើខ្ញុំនាំឱ្យខ្ញុំក្រៀមក្រំចិត្តជាខ្លាំង ។ ភាសាដែលខ្ញុំនិយាយក៏នាំឱ្យគាត់ត្មះតិះដៀលខ្ញុំដែរ ។

ខ្ញុំបានចេញពីផ្ទះបងសុនសន្ទាន ហើយទៅស៊ីឈ្នួលនៅផ្ទះចិនដែលនៅជិតផ្សារ។ ពេលនោះខ្ញុំឃើញគេអ្នកផ្សារស្លៀកពាក់ស្អាតៗ។ ម្ចាស់របស់ខ្ញុំមានកូនស្រីបីនាក់។

ខ្ញុំបាននៅបំរើគេ ដាំបាយ បោសផ្ទះ គក់ខោអាវ ប៉ុន្តែប្រាក់ខែរបស់ខ្ញុំតិចតួចណាស់ មិនអាចឱ្យខ្ញុំទិញខោអាវល្អៗស្លៀកពាក់ដូចគេឯងបានឡើយ។ កូនស្រីចៅហ្វាយខ្ញុំក៏មានខោអាវស្លៀកពាក់ស្អាតៗដែរ ។ខ្ញុំតែងតែលបមើលគេ ហើយខ្ញុំចង់បានខោអាវស្អាតៗស្លៀកពាក់ដែរ។ ថ្ងៃមួយប្អូនស្រីរបស់ចៅហ្វាយខ្ញុំមកលេង ។ មិនដឹងជានិស្ស័យអ្វី គ្រាន់តែឃើញគាត់ភ្លាម ខ្ញុំមានចិត្តចង់ទៅនៅជាមួយអ្នកនោះណាស់ ។ខ្ញុំគិតថាបើខ្ញុំទៅនៅជាមួយគាត់ ខ្ញុំប្រហែលជាបានធូរធារជាងសព្វថ្ងៃ ។ខ្ញុំបានសុំគាត់ឱ្យយកខ្ញុំទៅនៅជាមួយផង ។ ចៅហ្វាយខ្ញុំបានអនុញ្ញាតឱ្យខ្ញុំទៅនៅជាមួយប្អូនស្រីគាត់។ ចៅហ្វាយថ្មីរបស់ខ្ញុំនេះលក់ខោអាវនៅផ្សារ។ គាត់តែងឱ្យខ្ញុំនៅជួយលក់ខោអាវគាត់ ហើយឱ្យប្រាក់ខែល្មមតែខ្ញុំអាចទិញខោអាវស្លៀកពាក់បាន។ ខ្ញុំតែងតែខំជួយលក់គាត់ឱ្យដាច់ច្រើនដើម្បីឱ្យគាត់សប្បាយចិត្តផង ហើយ នៅពេលដែលយើងលក់ដាច់ច្រើនប្រាក់ខែរបស់ខ្ញុំក៏ធូរធារទៅតាមនោះដែរ ។ខ្ញុំបានឱ្យប្រាក់ខែខ្ញុំទៅចៅហ្វាយខ្ញុំទុកឱ្យ ពីព្រោះខ្ញុំហូបចុកជាមួយគាត់ ។ប៉ុន្តែគាត់និយាយថា ឯងទុកចាយវាយចុះពីព្រោះឯងក៏ត្រូវមានលុយខ្លះៗដែរ។

នៅពេលដែលខ្ញុំលក់ខោអាវនៅផ្សារនេះខ្ញុំបានគាប់ចិត្តហើយមានស្នេហាជាមួយនឹងប្រុសថៃ។ គេបានលួងលោមខ្ញុំហើយឱ្យខ្ញុំឈប់ធ្វើការនៅហាងលក់ខោអាវ ឱ្យខ្ញុំទៅធ្វើការនៅបារ ។គេនិយាយថាធ្វើនៅបារទើបបានលុយច្រើន។ ហេតុតែខ្ញុំស្រ

-ឡាញ់គេជ្រុលពេកខ្ញុំព្រមតាមគេនិយាយទាំងអស់។ តាមពិតគេឱ្យខ្ញុំធ្វើការនៅបារដើម្បីរកលុយឱ្យគេសប្បាយកំសាន្ត ហើយគេមិនបាច់ធ្វើការងារអ្វីទេ ចាំតែហូបចុកដោយសារកម្លាំងរបស់ខ្ញុំ ។ មិនត្រឹមតែប៉ុណ្ណោះគេប្រច័ណ្ឌហើយប្រើកម្លាំងបាយមកលើខ្ញុំជារឿយៗ ។ កាលពីគេស្រឡាញ់ខ្ញុំជាដំបូងគេប្រើពាក្យផ្អែមល្ហែម ឱ្យខ្ញុំជឿឱ្យខ្ញុំយល់ថាខ្ញុំមានទីរំពឹងហើយ ប៉ុន្តែនៅពេលដែលយើងរស់នៅជាមួយគ្នាបានបន្តិច គេកាន់តែមើលងាយខ្ញុំ ថាខ្ញុំគ្មានចេះអ្វី ថាខ្ញុំល្ងង់ ។ តាំងពីទាហានខ្មែរសុរិនរើសយកខ្ញុំទៅឱ្យម្តាយគាត់ចិញ្ចឹមរហូតមកដល់ពេលនោះ ខ្ញុំគ្មានបញ្ជីជាតិ ហើយមិនដែលបានចូលសាលាទេ ។ ខ្ញុំគឺជានារីដែលរសាត់ដូចចក រស់នៅគ្មានច្បាប់ក្នុងស្រុកគេ ហើយដែលខ្ញុំខ្លួនឯងមិនដែលចាប់អារម្មណ៍ថាខ្លួនឯងជាមនុស្សដែលមាន ទោសទៀតផង។

នៅពេលដែលខ្ញុំធ្វើការនៅបារបាន៤-៥ឆ្នាំ ខ្ញុំក៏បានស្គាល់ភ្ញៀវជាជនជាតិជប៉ុនជាតិតៃវ៉ាន់ជាដើម ។ មាននារីដែលធ្វើការជាមួយខ្ញុំគេធ្វើលិខិតឆ្លងដែនទៅ តៃវ៉ាន់ទៅជប៉ុនដើម្បីធ្វើការ ។ គេបាននិយាយថានៅទីនោះយើងមានលត្ថភាពអាចរកលុយបានច្រើនផងបានរស់នៅយ៉ាងសប្បាយផង។ ដោយប្តីខ្ញុំរករឿងខ្ញុំខ្លាំង ពេកផងនិងដោយគិតថាបុរសនេះគ្មានអនាគតត្រកាលផងព្រោះគេចេះតែស៊ីនិងផឹកហើយនិងវាយដំខ្ញុំៗមិនអាចទ្រាំបានក៏សំរេចស្វែងរកសេចក្តីសុខសុភមង្គលរបស់ខ្ញុំដោយខ្លួនខ្ញុំ ។

មិត្តខ្ញុំបាននិយាយថា" ឆវីឯងម៉េចក៏មិនសាកល្បងទៅជប៉ុននឹងគេ ?ទៅៗក្រែង

បានសល់ លុយទិញផ្ទះសំបែងនឹងគេ" ។

ខ្ញុំថាខ្ញុំគ្មានបញ្ជីជាតិ គ្មានអ្វីសំគាល់ខ្លួនទាំងអស់ ធ្វើលិខិតឆ្លងដែនម៉េចនឹងកើត ? មិត្តខ្ញុំឆ្លើយថា" មិនបាច់ទេ ឱ្យតែឯងមានលុយឱ្យគេមួយហ្មឺនបាត គេធ្វើឱ្យហើយ" ។ ខ្ញុំមិនដឹងទាល់តែសោះថាគេនិយាយពីលិខិតឆ្លងដែនក្លែងក្លាយ ។ ខ្ញុំបានខ្ចីលុយថៅកែមួយហ្មឺនបាតយកទៅឱ្យអ្នករត់ការ ។ ខ្ញុំបានលិខិតឆ្លងដែនហើយបានធ្វើដំណើរ មកជប៉ុន នៅពេលដែលខ្ញុំមានអាយុ២៦ឆ្នាំ ពោលគឺ១៧ឆ្នាំក្រោយពីពេលដែលខ្ញុំចាកចេញពីប្រទេសកម្ពុជា ។

គេបានដឹកយើងទៅធ្វើការនៅបារ ហើយឱ្យយើងលក់ខ្លួនដែរ ដើម្បីឱ្យអាចឆាប់រកលុយសងគេរួច ។ ខ្ញុំតូចចិត្តនឹងវាសនារបស់ខ្ញុំជាខ្លាំងដែលរសាត់អណ្តែតហើយធ្លាក់មកដល់បាតាលបែបនេះ ។នៅពេលធ្វើការលក់ខ្លួនហើយប្រគល់ខ្លួនប្រាណឱ្យទៅមនុ-ស្ស ប្រុសដែលគួរឱ្យខ្ពើមល្អើមក៏តោងតែទ្រាំបិតភ្នែកហើយធ្វើដូចជាយើងពេញចិត្តនឹងគូដៃរបស់យើងហើយទ្រាំរហូតឱ្យគ្រប់កិច្ច ។មួយថ្ងៃប្រៀបបាននឹងមួយសត-វត្ស ។ មានយប់មួយខ្ញុំយល់សប្តិឃើញថាមានពស់សធំមួយមករឹតរួបខ្លួនខ្ញុំ ។ តាមធម្មតាជំនឿសៀមក្តីជំនឿខ្មែរក្តីគេគិតថាយើងដល់គូព្រេងពីអតីតជាតិរបស់យើងហើយ ។

បន្ទាប់ពីយល់សប្តិបាន៥-៦ថ្ងៃទៅមានថ្ងៃមួយមានបុរសមួយក្រុមចូលមកស៊ីផឹកនៅបាររបស់យើង ។ ខ្ញុំស្រែកយ៉ាង ហ៊ឺកហ៊ាក់ទទួលពួកគេ ។" សូមអញ្ជើញ" ។ នៅក្នុងនោះមានបុរសម្នាក់ខ្ពស់ មិនសូវមាត់កទេ ។ គេបែរមករកខ្ញុំ ហើយញញឹម ។

តាំងពីថ្ងៃនោះមក បុរសនោះតែងតែមកហាងរបស់យើងតែឯងហើយចុចឈ្មោះខ្ញុំឱ្យទៅនិយាយកំដរគេ។ ឱ្យខ្ញុំចាក់ស្រាឱ្យគេសួរនាំពីខ្ញុំ ។ ខ្ញុំតែងតែបុកពោះភឹប១ នៅពេលដែលខ្ញុំនិយាយជាមួយគេ។ ខ្ញុំហាក់ដូចជាស្រឡាញ់គេបន្តិច១ ។ ខ្ញុំបានសាកសួរគេពីគ្រួសាររបស់គេ ។ គេនិយាយថាគេនៅកំឡោះទេ ។តាំងពីដាក់ជើងមកជាន់ដីជប៉ុននេះមកខ្ញុំហាក់ដូចជាចេះតែស្រមៃឃើញថាខ្ញុំនឹងអាចចាប់បាននូវជីវិតមួយដែលពោរពេញទៅដោយសុភមង្គលដូចជីវិតដែលខ្ញុំតែងតែមានកាលពីខ្ញុំនៅជាមួយឪពុកម្ដាយខ្ញុំ កាលពីខ្ញុំនៅជាកុមារនៅឡើយ ។ខ្ញុំបានសំរេចចិត្តហើយថា ខ្ញុំត្រូវតែមានសុភមង្គល ។ខ្ញុំស្មាលាជីវភាពរស់នៅដែលមិនដឹងថាខ្លួនឯងជាអ្វីដែលខ្ញុំធ្លាប់មានក្នុងរយៈពេល១៧ឆ្នាំមុនមកនេះ។

ប៉ុន្តែខ្ញុំមិនជាក់ក្នុងចិត្តថាបុរសជប៉ុននេះនឹងទទួលយក ខ្ញុំដែលជានារីបារទៅធ្វើជាភរិយាគេឬអត់ទេហើយបើគេព្រមមែនក៏គង់គ្រួសាររបស់គេប្រឆាំងមិនលែងឡើយ ។ ខ្ញុំខំស្ទៀបស្ទង់មើលទឹកចិត្តរបស់បុរសជាភ្ញៀវរបស់ខ្ញុំ ដែលតែងតែចំណាយលុយយ៉ាងច្រើនដើម្បីមកនិយាយលេងជាមួយខ្ញុំមកទទួលទានស្រា ហើយខ្ញុំទៅជាអាណិតគេចម្លែក ។ នៅថ្ងៃមួយ គេបានសួរខ្ញុំថា តើខ្ញុំមានប្ដីឬសង្សារឬនៅ ? ខ្ញុំបានឆ្លើយថាខ្ញុំគ្មានទេខ្ញុំនៅតែម្នាក់ឯង ។គេសួរខ្ញុំទៀតថា តើខ្ញុំមានបំណងនឹងរស់នៅស្រុកជប៉ុនជាមួយគេទេ?ខ្ញុំអរភើតខ្ញុំមិននឹកស្មានថាវាសនាដ៏អាភ័ព្វរបស់ខ្ញុំអាចបញ្ចប់ត្រឹមនេះបានយ៉ាងស្រួលធូរល្ហយបែបនេះឡើយ ។ ប៉ុន្តែថ្ងៃនោះគេសួរតែប៉ុននេះក៏លាទៅវិញ ហើយឈប់មកហាង មួយរយៈធំ។

ប្រហែលជាពីរ-បីខែកន្លងទៅគេបានមកហាងយើងហើយទិញចិញ្ចៀនមួយដ៏ល្អផ្ញើរខ្ញុំ ។ជាមួយនឹងចិញ្ចៀនគេបានសរសេរលេខទូរស័ព្ទរបស់គេឱ្យខ្ញុំទូរស័ព្ទទៅគេ ។ វិន័យនៅក្នុងបារតឹងរ៉ឹងណាស់ ។ យើងមិនអាចទាក់ទងនឹងភ្ញៀវផ្ទាល់ដោយមិនឆ្លងកាត់តាមម្ចាស់បារឡើយ ។ ប៉ុន្តែដើម្បីសុភមង្គលជានិរន្តរបស់ខ្ញុំ ៗសុខចិត្តឱ្យគេជេរខ្ញុំមួយគ្រាសិនចុះ ។ខ្ញុំធ្វើជាឈឺផ្ដាសាយហើយសុំថៅកែឈប់ដើម្បីទៅជួបនឹងម្ចាស់ព្រេង វាសនារបស់ខ្ញុំ ។

ខ្ញុំបានណាត់ជួបលោកសាតូដែលជាអតីតម៉ូយខ្ញុំនិងជាអនាគតស្វាមីរបស់ខ្ញុំនៅហាងកាហ្វេដ៏ថ្លៃថ្នូរមួយនៅអាមា៉ង៉ាសាគី ។ លោកសាតូបានសាកសួរពីទឹកចិត្តពិតរបស់ខ្ញុំចំពោះគាត់ ។ ខ្ញុំរំភើបចិត្តណាស់ខ្ញុំមិនអាចទប់ទឹកភ្នែករបស់ខ្ញុំកុំឱ្យវាច្រាលឡើងមកបានឡើយ ។ អ្នកផងតែងតែនិយាយថាទឹកភ្នែកស្រីបារជាទឹកភ្នែកក្រពើ ។ ខ្ញុំត្រូវ បានគេចាត់ទុកជាសត្វតិរិច្ឆានគ្រប់សព្វអស់ហើយ ៗ ។ ទោះជាគេហៅខ្ញុំថាជីងចក់ក្ដីនៅពេលខ្ញុំអត់ឃ្លានក៏ខ្ញុំទ្រាំដែរបានដើម្បីតែបាយមួយកូនចាននិងកូនត្រីប្រៃមួយកន្ទុយ ចុះទំរាំដល់ទៅដើម្បីជាថ្នូរនឹងសុភមង្គលមួយជីវិត តើខ្ញុំមិនអាចទ្រាំនឹងពាក្យដែលគេហៅថាក្រពើមួយម៉ាត់នេះកើតឬ? តាមពិតទៅទឹកភ្នែករបស់ខ្ញុំជាទឹកភ្នែកដែលកើតពីក្ដីរំភើបជ្រុលពេកតែប៉ុណ្ណោះព្រោះខ្ញុំក៏បានលបលួចប្រតិព័ទ្ធទៅលើលោកសាតូជាយូរហើយដែរហើយខ្ញុំគិតថាអាពាហពិពាហ៍រវាងយើងទាំងពីរអាចនាំឱ្យខ្ញុំប្ដូរភាពពីសត្វទៅជាមនុស្សពេញសិទ្ធម្នាក់ ដែលមិនចាំបាច់រស់ដោយលួចលាក់ដូចកណ្ដុរទៀតឡើយ ។ ជយោ! ពីថ្ងៃនេះទៅខ្ញុំឈប់ឈ្មោះយោកូ ( ឈ្មោះជប៉ុនដែល

មេបារបានដាក់ឱ្យខ្ញុំពេលខ្ញុំមកធ្វើការឱ្យគេភ្លាម) ខ្ញុំឈប់ឈ្មោះឆវី ម៉ានីវ៉ាន់ទៀត ហើយខ្ញុំនឹងមានឈ្មោះថាឈ្មួនអារីយ៉ាឡាវ៉ាត់ដែលម្តាយឪពុកខ្ញុំបានដាក់ឱ្យខ្ញុំពីកំណើ-តមក។

## ជំពូកទី៣

ឧបស័គ្គ

យើងមិនបានធ្វើពិធីមង្គលការធំដុំទេ យើងគ្រាន់តែអញ្ជើញក្រុមគ្រួសារខាងប្រុស នឹងញាតិមិត្តប៉ុន្មានអ្នកមកទទួលទានអាហារជុំគ្នាតែប៉ុណ្ណោះ។

ខ្ញុំសំគាល់ឃើញថាគ្រួសារខាងស្វាមីខ្ញុំក៏មិនជាមានធូរធារប៉ុន្មានដែរ ហើយគេដូចជា មិនសូវមានការរាក់ទាក់គួរសមជាមួយខ្ញុំប៉ុន្មានដែរ ។ម្នាក់ៗមើលមកខ្ញុំថាជាស្រីបារ ដែលរកបោកប្រាសលោកសាតូ ដើម្បីតែយកវីសាសំរាប់រស់នៅប្រទេសជប៉ុនមួយ គ្រាហើយនឹងដាក់មេផាយទៅ រកម៉ូយដែលគ្រាន់បើជាងនេះតែប៉ុណ្ណោះ។ ខ្ញុំនិយាយ បែបនេះហាក់ដូចជាមើលឃើញតែពិភពលោកខ្មៅងងឹតតែម្យ៉ាង។ ប៉ុន្តែការពិត គឺអញ្ចឹង ។ នេះម្យ៉ាងហើយប៉ុន្តែអ្វីដែលខ្ញុំនឹកមិនដល់គឺការរត់បែបបទ។ នៅពេល ដែលយើងទៅចុះអេតាស៊ីវីលខ្ញុំមានតែលិខិតឆ្លងដែនមួយសន្លឹកតឹកឡឹកតឹកឡឹក តែ ប៉ុណ្ណោះ ។មេបារបានហាមខ្ញុំកុំឱ្យយកទៅស្ថានទូតថៃព្រោះលិខិតឆ្លងដែននេះជារបស់ ក្លែងក្លាយទេ ។អញ្ចឹងតើឱ្យខ្ញុំធ្វើយ៉ាងម៉េច?

ខ្ញុំបានគិតថាលិខិតឆ្លងដែនរបស់ខ្ញុំជាអត្តសញ្ញាណប័ណ្ណសំរាប់សំគាល់ខ្លួនខ្ញុំ មិនដឹងអី ថាជារបស់ក្លែងក្លាយ ។ បើរដ្ឋាភិបាលជប៉ុនដឹងគេនឹងឱ្យប៉ូលីសមកចាប់ខ្ញុំយកខ្ញុំទៅ ដាក់គុកទៅហើយ? ខ្ញុំទើបនឹងដឹងច្បាស់ថារូបខ្ញុំនេះមានតែរូបទេប៉ុន្តែគ្មានជំរឿននៅ ក្នុងស្ថិតិប្រជាជននៃប្រទេសណាមួយទេ។ ខ្ញុំទៅជាស្លន់ស្លោរ ហែកលិខិតឆ្លងដែន ខ្ញុំបំបាត់តាងហើយខ្ញុំអស់សង្ឃឹមធេងមិនដឹងត្រូវដើរផ្លូវណាទេ។ ខ្ញុំយំឱបប្តីខ្ញុំ ៗមិន

អាចពន្លែងសុភមង្គលដែលខ្ញុំក្តាប់ជិតជាប់ហើយឱ្យរបូតចេញពីដៃខ្ញុំទៅវិញបានទេ។
-បង ជួយអូនផង។ បងកុំចោលអូន ៗគ្មាននរណាជាទីរំពឹងទេ។ បងជួយអូនផង។

ខ្ញុំឱបប្តីខ្ញុំមិនលែងយំកន្ទក់កន្ទិញព្រោះខ្ញុំភ័យណាស់ ខ្ញុំនឹងជាប់គុកងងឹតមួយជីវិតទេដឹង។ សុបិនអាក្រក់ដែលខ្ញុំបានឃើញនៅជំនាន់ពលពតបានបញ្ចេញរូបរាងជាថ្មីមកឱ្យខ្ញុំបារម្ភ ខ្លាចតែត្រូវរស់នៅតែឯង ឬក៏ត្រូវគេបញ្ជូនទៅស្រុកថៃដាក់គុកបែកពីប្តីខ្ញុំ។ ខ្ញុំយំបណ្តើរនិយាយរឿងរ៉ាវរបស់ខ្ញុំពីដើមដល់ចប់ឱ្យប្តីខ្ញុំស្តាប់បណ្តើរ។ ប្តីខ្ញុំយំឱបខ្ញុំព្រោះអាណិតខ្ញុំខ្លោចចិត្តមិននឹកស្មានថានៅក្នុងលោកនេះមានរឿងបែបនេះ។ ប្តីខ្ញុំនិយាយថា :
-បងនឹងហៅអូនថាអារីយ៉ា អូនមិនមែនយោកូទេ។ អូនជាខ្មែរដូច្នេះអូនទៅពិគ្រោះជាមួយនឹងស្ថានទូតខ្មែរលមើល។

ខ្ញុំបានទូរស័ព្ទទៅស្ថានទូតខ្មែរ ។ លោកដែលកាន់ខាងកុងស៊ុលគឺលោកកាន់ណារ៉ាបានបញ្ជូនរឿងខ្ញុំទៅឱ្យបុគ្គលិកស្ថានទូតម្នាក់ទៀតដែលចេះភាសាថៃឱ្យសួរនាំពីខ្ញុំ ។ លោកនោះឈ្មោះលោកផាណារិន។ លោកផាណារិនបានហៅខ្ញុំឱ្យឡើងមកតូក្យូ។

ខ្ញុំបានរួសរាន់ឡើងមកតូក្យូដោយជិះស៊ីនកាន់សេង(រទេះភ្លើងកាំរស្មី)កាត់តាមអូសាកាតែឯកឯងមកហើយដើររកស្ថានទូតខ្មែរដែលនៅកណ្តាលក្រុង។

នៅពេលដែលខ្ញុំបើកទ្វារស្ថានទូតចូលទៅ មានបុរសក្មេងម្នាក់មានជើងពិការចេញមកទទួលខ្ញុំ ។ នោះហើយគឺបងផាណារិន។ នៅពេលដែលឱ្យខ្ញុំអង្គុយស្រួលបួល

ហើយ បងផាណារិនក៏ឱ្យខ្ញុំបញ្ចេញលិខិតស្នាមដែលខ្ញុំមាន ។ ខ្ញុំនិយាយថាខ្ញុំគ្មានអ្វីទេបង។ បងផាណារិនថាបើគ្មានអ្វីអញ្ចឹង ខ្ញុំមិនដឹងជួយដោយវិធីណាទេ ។ ឮដូច្នេះអ្វីៗដែលនៅមុខខ្ញុំឡើងខ្មៅរល ខ្ញុំទ្រហោយំដោយអស់សង្ឃឹម ។

-ជួយខ្ញុំផងបង ខ្ញុំមិនដឹងទៅរកអ្នកណាទេបង មានតែស្ថានទូតយើងនេះហើយដែលជាទីកដីរបស់ខ្ញុំ ជួយខ្ញុំផងបង។

បងផាណារិនឱ្យខ្ញុំអង្គុយចាំ ហើយទៅពិគ្រោះជាមួយនឹងលោកកាន៉ណាវ៉ា ។ លោកកាន់ណាវ៉ាបានចូលមកបន្ទប់ដែលខ្ញុំអង្គុយហើយចាប់ផ្តើមធ្វើសម្ភាសន៍ជាមួយខ្ញុំ។ គាត់សួរខ្ញុំតាំងពីកន្លែងកំណើត ឈ្មោះឪពុកម្តាយ កន្លែងដែលគេជន្លៀសខ្ញុំទៅ។ ពូកាន់ណាវ៉ានិយាយថា " អូខ្ញុំស្គាល់ ភូមិនោះជាភូមិដែលខ្ញុំទៅរស់នៅដែរ ពិបាកណាស់ខ្ញុំដឹងហើយ។ យើងនិយាយត្រូវគ្នារហូត ។ ពូកាន៉ណាវ៉ាបានចារអ្វីៗដែលខ្ញុំនិយាយទាំងអស់ទុក។ រួចមកគាត់ឱ្យខ្ញុំត្រឡប់ទៅអាម៉ាង៉ាសាគីវិញចុះចាំគាត់ពិគ្រោះជាមួយចៅហ្វាយខាងលើរបស់គាត់សិន។

បន្ទាប់មកពូកាន់ណាវ៉ាបានរត់ការ កាត់តាមចៅក្រមកំពូលនៃព្រះរាជាណាចក្រកម្ពុជា តាមអគ្គស្នងការប៉ូលីសហើយមិនត្រឹមតែបានបញ្ជាក់ថាខ្ញុំជាជនជាតិខ្មែរពេញសិទ្ធិតែប៉ុណ្ណោះទេថែមទាំងបានផ្តល់លិខិតឆ្លងដែនឱ្យមកខ្ញុំថែមទៅទៀត ។ ខ្ញុំបានសញ្ជាតិជាខ្មែរហើយប៉ុន្តែមិនមែនអាចបញ្ចប់រឿងបានទេ ។ប៉ូលីសសម្ងាត់ជប៉ុនបានមកចាប់ខ្ញុំនៅផ្ទះពីបទដែលខ្ញុំចូលប្រទេសជប៉ុនដោយលិខិតឆ្លងដែនក្លែងក្លាយរួចហើយគេឱ្យខ្ញុំឡើងតុលាការ។ អជ្ញាសាលាបានសូត្រពីបទល្មើសដែលខ្ញុំបានប្រព្រឹត្ត

ហើយសាលាកាត់ក្តីកាត់ទោសខ្ញុំ១ឆ្នាំ៦ខែ ។ក្នុងរយៈកាលបីឆ្នាំបើខ្ញុំជាប្រជាជនល្អក្នុងប្រទេសជប៉ុនខ្ញុំអាចចាកទោសនេះបាន ។ក៏ប៉ុន្តែឈ្មោះខ្ញុំជាប់នៅក្នុងបញ្ជីខ្មៅរបស់ប៉ូលីសជានិច្ចជាកាលហើយគេនឹងតាមដានខ្ញុំរហូត ។

មុននឹងលាចាកដំណែងទៅប្រទេសជាតិវិញពូកាន់ណាវ៉ាបានផ្តាំខ្ញុំថាបើអស់ពីគាត់មានការអ្វីសូមទូរស័ព្ទទាក់ទងសាស្ត្រាចារ្យប៉ែនសេដ្ឋារិនទៅគាត់នឹងជួយហើយ ។ នៅពេល ដែលមានរឿងអ្វីខ្ញុំតែងតែនឹកដល់សន្តានចិត្តដ៏ល្អរបស់បងខ្មែរ១ទាំងឡាយដែលខ្ញុំបានជួប ហើយខ្ញុំគិតថាសន្តានចិត្តចេះជួយឈឺឆ្អាលគ្នានេះហើយជាសន្តានចិត្តខ្មែរឱ្យខ្ញុំនៅតែចងចាំឈាមជ័រជាខ្មែររបស់ខ្ញុំទោះបីខ្ញុំចេះភាសាថៃជាងភាសាខ្មែរក៏ដោយ ។

រឿងខ្ញុំមិនទាន់ចប់ទេ ។ជីវភាពខ្ញុំនៅជប៉ុនជាមួយគ្រួសារប្តីខ្ញុំជាសោកនាដកម្មមួយទៀត ប៉ុន្តែខ្ញុំអាច ទ្រាំទ្របានដោយការខំទ្រាំ ឬការខំប្រឹងប្រែងដោយកំឡាំងខ្លួនឯង ។ ប៉ុន្តែបញ្ហានានា ដែលទាក់ទងនឹងរឿងទៅបន្តលិខិតឆ្លងដែននៅកម្ពុជាជាដើមរឿងឱ្យគេបញ្ជាក់ពីបញ្ជីជាតិរបស់ខ្ញុំគឺជារឿងដែលខ្ញុំតោងតែពឹងកម្លាំងស្ថានទូតឬអ្នកផ្សេងហើយខ្ញុំកាន់តែដឹងថាខ្ញុំម្នាក់ឯងទោះជាខំប្រឹងទាល់តែស្លាប់ខ្លួនក្តីបើស្ថានទូតខ្មែរ ប្រទេសខ្មែរ មិនទទួលស្គាល់ថាខ្ញុំជាខ្មែរទេប្រហែលជាមិនដឹង ជាត្រូវទៅជាអ្វីទេ ។ នេះហើយកេរមរតកនៃមនោគមវិជ្ជា និងសង្គ្រាម ។